# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង
## រវាង តំណាងបុគ្គលិក សណ្ឋាគារ សុខាអង្គរ
## និង និយោជកនៃ សណ្ឋាគារ សុខាអង្គរ

អនុស្សរណៈនៃការយោគយល់នេះត្រូវបានធ្វើឡើងនៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០២០ រវាងប្រធានផ្នែកនៃសណ្ឋាគារ សុខាអង្គរ (ពីនេះតទៅហៅថា "តំណាងបុគ្គលិក") និងតំណាងសណ្ឋាគារ សុខា អង្គរ (ពីនេះតទៅហៅថា "និយោជក")។

ដោយសារស្ថានភាពវិបត្តិជំងឺ Covid-19 នៅលើពិភពលោកនៅតែពុំទាន់ថមថយ ធ្វើអោយប្រក្រតីភាពនៃដំណើរការសេដ្ឋកិច្ច និងពាណិជ្ជកម្មគ្រប់វិស័យនៅលើពិភពលោក រួមទាំងប្រទេសកម្ពុជាយើងផងនៅតែទទួលរងនូវបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរ ជាពិសេសលើវិស័យទេសចរណ៍ និងបដិសណ្ឋាកិច្ច។ អាស្រ័យហេតុនេះយើងខ្ញុំបានសម្រេចចិត្តផ្អាកសកម្មភាពអាជីវកម្មរបស់ សណ្ឋាគារ សុខាអង្គរ ជាបណ្តោះអាសន្នរយៈពេលពីរ(០២)ខែបន្តទៀត ដោយគិតចាប់ពីថ្ងៃទី០១ ខែសីហា រហូតដល់ថ្ងៃទី៣០ កញ្ញា ឆ្នាំ២០២០ ។ ហេតុនេះ ដើម្បីសម្រាលនូវបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរនៅចំពោះមុខនេះ និយោជក និងតំណាងបុគ្គលិកបានចរចារ និងព្រមព្រាងគ្នាដាក់ឲ្យបុគ្គលិកចំនួន ២២៨នាក់ ស្រី ៨៨នាក់ បន្តឈប់សម្រាកពីការងារដោយឥតប្រាក់ឈ្នួល រយៈពេលពីរ (២) ខែទៀត គិតចាប់ពីថ្ងៃទី ០១ ខែសីហា ដល់ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០។

ភាគីទាំងពីរបានព្រមព្រៀងគ្នា លើលក្ខខណ្ឌដូចខាងក្រោម៖

- និយោជិតដែលត្រូវបានដាក់ឲ្យឈប់សម្រាកពីការងាររយៈពេលពីរ (២) ខែ នឹងមិនទទួលបានប្រាក់ឈ្នួល និងប្រាក់ធានានុគ្រោះទេ នៅក្នុងអំឡុងពេលនៃការឈប់សម្រាកនេះ។
- និយោជកនឹងផ្តល់ប្រាក់ឧបត្ថម្ភដល់និយោជិតម្នាក់ៗចំនួន២០ដុល្លារ
  ចំពោះនិយោជិតដែលត្រូវរក្សាទុកក្នុងចំនួនអប្បបរមា ទៅតាមតម្រូវការជាក់ស្តែងនៃផ្នែកនីមួយៗសម្រាប់ធ្វើការពេញម៉ោង (៤សប្តាហ៍) ក្នុងមួយខែ៖
- និយោជិតធម្មតានឹងទទួលបានប្រាក់ឈ្នួល ១០០% ព្រមទាំងប្រាក់ ឧបត្ថម្ភអាហារចំនួន ២.០០ដុល្លារអាមេរិក សម្រាប់ ១ថ្ងៃធ្វើការ។
- អនុប្រធានផ្នែកវិស្វកម្ម នឹងទទួលបានប្រាក់ឈ្នួល ៥០% នៃប្រាក់ខែគោល ព្រមទាំងប្រាក់ឧបត្ថម្ភអាហារចំនួន ៥.០០ដុល្លារអាមេរិក សម្រាប់ ១ថ្ងៃធ្វើការ។
- និយោជិតថ្នាក់ប្រធាន/អនុប្រធានផ្នែក ដែលតម្រូវឲ្យធ្វើការបួន (៤) ថ្ងៃក្នុងមួយខែ នឹងទទួលបានប្រាក់ឈ្នួល ៥០% នៃប្រាក់ខែគោល ដោយគណនាទៅតាមចំនួនថ្ងៃធ្វើការជាក់ស្តែងរបស់និយោជិតនីមួយៗ ព្រមទាំងប្រាក់ឧបត្ថម្ភអាហារចំនួន ៥.០០ដុល្លារអាមេរិក សម្រាប់ ១ថ្ងៃ

សណ្ឋាគារសុខាអង្គរ
SOKHA ANGKOR HOTEL
BRANCH OF SOKHA HOTEL CO.LTD.

ធ្វើការ។

- និយោជិតថ្នាក់គ្រប់គ្រងទូទៅ និងគ្រប់គ្រងប្រតិបត្តិការត្រូវធ្វើការពេញម៉ោង ដោយទទួលបានប្រាក់បៀវត្ស២០% ព្រមទាំងប្រាក់ ឧបត្ថម្ភអាហារចំនួន ៥.០០ដុល្លារអាមេរិក សម្រាប់ ១ថ្ងៃធ្វើការ។

សូមបញ្ជាក់ថា ចំណុចដូចដែលបានរៀបរាប់ខាងលើនេះ គឺសម្រាប់ការអនុវត្តរយៈពេលពីរ (២) ខែ គិតចាប់ពីថ្ងៃទី០១ ខែសីហា ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០។ ក្រុមហ៊ុននឹងធ្វើការជូនដំណឹងជាថ្មី ប្រសិនបើស្ថានការណ៍មានការប្រែប្រួល ហើយគូភាគីនឹងពិនិត្យមើលអនុស្សរណៈនៃការឯកភាពនេះ ពីខាងក្រោមនេះ៖

**ហត្ថលេខាភាគីតំណាងនិយោជក**

________________

**ហត្ថលេខាភាគីតំណាងនិយោជិត**

សុខ សារ៉ាយុទ្ធ ________________

អ៊ុក សុធា ________________

វ៉ាន់ ចំណាន ________________

សាយ មុន្នី ________________

ប៊ិន់ សាលីន ________________

កាន់ គង់ហេង ________________

អ៊ូ ស៊ុក ________________

គង់ សុខា________________